ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយ
# គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច

## រួបរួមជាតិ ដើម្បី
## កម្ពុជា ឯករាជ្យ អព្យាក្រឹត សន្តិ និង សហប្រតិបត្តិ ឆ្ពោះទៅរកការកសាង
## និងអភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា

# **បុព្វកថា**

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ជាគណបក្សនយោបាយ ដែលបានប្រសូត្រចេញ ពីចលនាតស៊ូរំដោះជាតិគឺ រណសិរ្សរួបរួមជាតិ ដើម្បីកម្ពុជា ឯករាជ្យ អព្យាក្រឹត សន្តិ និងសហប្រតិបត្តិ "រជកឯអសស" (Front Uni National pour un Cambodge Independant, Neutre, Pacifique et Cooperatif "FUNCINPEC") ដែលបានបង្កើតឡើង ដោយព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ នៅថ្ងៃទី២១ ខែមិនា ឆ្នាំ១៩៨១ ហើយត្រូវបានប្តូរមកជា **គណបក្សហ្វ៊ុនស៊ិនប៉ិច** នាពេលសមាជសាកល នៅថ្ងៃទី២៧-២៩ ខែកុម្ភៈ ឆ្នាំ១៩៩២ នៅភូមិត្រុំ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** មានគោលការណ៍ដឹកនាំប្រទេសជាតិ តាមមាគ៌ា **នយោបាយសីហនុនិយម។**

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ជាភាគីមួយក្នុងចំណោមភាគីហត្ថលេខី នៃកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងបារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ស្តីពីបញ្ហាកម្ពុជា។ ស្តែងចេញពីសាមគ្គីភាព នៃអ្នករាជានិយម អ្នកសីហនុនិយម **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ទទួលបានជោគជ័យ នាំមុខគេ ក្នុងការបោះឆ្នោតសាកលថ្ងៃទី២៣-២៧ ខែឧសភា ឆ្នាំ១៩៩៣។ ជ័យជំនះរបស់**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ជាជ័យជំនះរបស់ប្រជាជាតិខ្មែរទាំងមូល ។ បន្ទាប់ពីទទួលបានជ័យជំនះ ក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ និងដោយទទួលបានការសព្វព្រះរាជហឫទ័យពីសម្តេចឪ សម្តេចតា សម្តេចតាទួត ព្រះមហាវីរក្សត្រនៃយើង **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** បានចូលរួមយ៉ាងសកម្ម ក្នុងការបង្កើតរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បង្កើតរបបរាជានិយម អាស្រ័យដោយរដ្ឋធម្មនុញ្ញ ប្រកាន់យកនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារ។

ដោយមានការរួបរួមគ្នា និងមានការឯកភាព នៃអ្នករាជានិយម អ្នកសីហនុនិយមឡើងវិញ ក្នុងការពង្រឹងគណបក្សសម្រាប់ការបោះឆ្នោតសាកល នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ខាងមុខ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** សូមដាក់ជូននូវគោលនយោបាយដូចតទៅ ៖

១ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ជាគណបក្សរាជានិយម ការពាររបបរាជានិយម គោរព និងការពាររដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ដែលមានព្រះមហាក្សត្រជានិមិត្តរូបនៃសាមគ្គីភាព ឯកភាពជាតិ អធិបតេយ្យ និងបូរណភាព ទឹកដី និងយុត្តិធម៌សង្គម។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** គោរពគ្រប់គោលការណ៍ស្តីពីព្រះរាជបុព្វសិទ្ធិ នៃព្រះមហាក្សត្រស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

២ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** លើកស្ទួយនិងអនុវត្តមាគ៌ានយោបាយសីហានុនិយម ក្នុងការកសាង ស្ថាបនា និងអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យបានរុងរឿងថ្កើងថ្កាន ដូចមានគំរូ ដឹកនាំក្នុងសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចឪ សម្តេចតា សម្តេចតាទួត ព្រះមហាវីរក្សត្រនៃយើង ដែលជាព្រះបិតាស្ថាបនិកហ្វ៊ុនស៊ិនប៉ិច។

មាគ៌ានយោបាយរាជានិយម សីហានុនិយម គឺនយោបាយជាតិ បង្រួបបង្រួមខ្មែរគ្រប់និន្នាការ នយោបាយក្នុងក្របខណ្ឌផ្សះផ្សាជាតិ ឯកភាពជាតិ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍ ឯករាជ្យ អព្យាក្រឹតសន្តិភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសលើសាកលលោក ដោយគោរពអធិបតេយ្យនិងបូរណភាពទឹកដី។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ប្តេជ្ញាដើរតាមមាគ៌ាអហឹង្សា ដើម្បីបង្កើតសន្តិភាព ផ្សះផ្សាជាតិនិងឯកភាពជាតិ ដូចដែលសម្តេចឪ សម្តេចតា ព្រះមហាវីរក្សត្រនៃយើង មានព្រះតម្រិះត្រួសត្រាយដឹកនាំជូនជាតិជាគំរូ ដើម្បីឲ្យប្រជារាស្ត្របានសុខសប្បាយ ជីវភាពធូរធារ ប្រទេសជាតិមានការអភិវឌ្ឍក្នុងសន្តិភាព។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** បង្កើនការគោរព និងលើកតម្កើងព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ព្រមទាំងគោរពសិទ្ធិ និងជំនឿលើសាសនាដ៏ទៃទៀតដែរ។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ប្រកាន់យកមាគ៌ាអហឹង្សា ដើម្បី ដោះស្រាយនូវរាល់ បញ្ហាសង្គមដោយគោរពសិទ្ធិ និងសេរីភាពរបស់ប្រជារាស្ត្រ និងបញ្ចៀសនូវអំពើហឹង្សាក្នុងគ្រួសារ និងក្នុងសង្គមពង្រឹងសីលធម៌សង្គម និងបណ្តុះមនសិការស្នេហាជាតិ ស្នេហាវប្បធម៌ អហឹង្សា និងការយោគយល់គ្នាក្នុងមហាគ្រួសារខ្មែរ ស្របតាមព្រះពុទ្ធ វចនៈ ស្តីពីព្រហ្មវិហារធម៌ ។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** យល់ថា សន្តិភាព គឺជាគ្រឹះនៃការអភិវឌ្ឍ ហើយដែលផ្តើមចេញដំបូងពីសន្តិភាពនៅក្នុងចិត្ត របស់បុគ្គលម្នាក់ៗ។

៣ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ប្រកាន់យកនយោបាយបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ឯករាជ្យអព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ និងធ្វើទំនាក់ទំនងជាមួយបណ្តាប្រទេសនានាលើ សាកលលោក។

នយោបាយរួបរួមជាតិ ផ្សះផ្សាជាតិ គឺនយោបាយមិនរើសអើងពណ៌សម្បុរ និន្នាការនយោបាយ ជំនឿសាសនា និងប្រពៃណីទំនៀមទំលាប់ ។ ប្រជារាស្ត្រខ្មែរគ្រប់រូប មានសិទ្ធិចូលរួម ក្នុងវិស័យ នយោបាយ

សេដ្ឋកិច្ច សង្គមកិច្ច និងការពារជាតិ ដើម្បីធានាបាននូវឯកភាពជាតិ យុត្តិធម៌សង្គម ការអភិវឌ្ឍ និងការអនុវត្តគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

**គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** ប្រកាន់យកនយោបាយឯករាជ្យ អព្យាក្រឹត គឺឈរលើនយោបាយ អធិបតេយ្យ និងបូរណភាពជាតិ ក្នុងការគ្រប់គ្រងនិងដឹកនាំប្រទេស និងប្តេជ្ញាធ្វើឲ្យអំណាច នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ដាច់ដោយឡែកពីគ្នា។

**គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** អនុវត្តគោលនយោបាយ ការបរទេស សន្តិ សហវិជ្ជមាន ដោយផ្អែកលើឯករាជ្យ អព្យាក្រឹត អធិបតេយ្យ និងបូរណភាពទឹកដី នៃប្រទេសកម្ពុជា និងដោយមិនអនុញ្ញាតឲ្យមានការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងពីបរទេស ហើយក៏ពុំជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង ប្រទេសដទៃ។

៤ **គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** លើកស្ទួយ និងការពារសន្តិភាព ស្ថិរភាពនយោបាយ ការអភិវឌ្ឍ អធិបតេយ្យភាព និងបូរណភាពទឹកដី។

**គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** រក្សានិងបន្តដង្ហែតាមព្រះរាជតម្រិះ និងព្រះរាជមាគ៌ានយោបាយ សម្តេចឪ សម្តេចតា សម្តេចតាទួត ព្រះមហាវីរក្សត្រនៃយើង ដោយហ៊ានលះបង់ផលប្រយោជន៍ ផ្ទាល់ខ្លួន និងធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុសន្តិភាព ស្ថិរភាពនយោបាយ ការផ្សះផ្សាជាតិ ឯកភាពជាតិ និងការអភិវឌ្ឍ កាត់បន្ថយភាពក្រីក្រ ធ្វើឲ្យប្រជារាស្ត្រមានជីវភាពធូរធារ សម្បូរសប្បាយ ដែលជាសេចក្តីត្រូវការ និងជាបំណង ប្រាថ្នារបស់ប្រជារាស្ត្រខ្មែរ ។ **គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** យល់ថា មានសន្តិភាព ស្ថិរភាព ផ្សះផ្សាជាតិ និងឯកភាពជាតិ ទើបយើងអាចធ្វើការអភិវឌ្ឍ និងការពារបាននូវ អធិបតេយ្យ និងបូរណភាពទឹកដី។

៥ **គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** ជម្រុញការគោរពសិទ្ធិមនុស្ស និងការគោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ឲ្យបានល្អប្រសើរ សំដៅឲ្យមជ្ឈដ្ឋានជាតិ និង អន្តរជាតិ ទទួលយកបានដូចបណ្តាអារ្យប្រទេសលើសាកលលោក ស្របតាមរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិមនុស្ស។

៦ **គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** លើកកម្ពស់ស្ត្រីចូលរួមក្នុងវិស័យនយោបាយ និងចូលរួមដឹកនាំគ្រប់វិស័យ និងគ្រប់លំដាប់ថ្នាក់ គឺផ្តើមចេញពីនយោបាយមាតាធិបតេយ្យ និងជាពិសេសត្រូវលើកទឹកចិត្ត ឲ្យកូនស្រីបានចូលរៀនសូត្រដូចកូនប្រុស។

៧ **គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** ដង្ហែតាមព្រះរាជតម្រិះសម្តេចឪ សម្តេចតា សម្តេច តាទួត ព្រះមហាវីរក្សត្រនៃយើង គឺចាត់ទុកបងប្អូនខ្មែរកម្ពុជាក្រោម ជាខ្មែរពេញសិទ្ធិ។

បងប្អូនខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសិទ្ធិទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ ដូចប្រជារាស្ត្រខ្មែរ

យើងដែរ។

៨ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** មានគោលការណ៍អភិវឌ្ឍប្រទេសជាតិ ដោយឈរ លើធនធានទាំងបីរបស់ជាតិ គឺធនធានមនុស្ស ធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ ។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ដោះស្រាយប្រាក់បៀវត្ស ឲ្យបានសមរម្យជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងកម្មករ ដើម្បីឲ្យមានកំរិត ជីវភាពគ្រប់គ្រាន់ ស្របតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចទីផ្សារ។

៩ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** អភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយពង្រីកនិងគ្រប់គ្រង ទេសចរណ៍ធម្មជាតិ ទេសចរណ៍វប្បធម៌ និងអភិវឌ្ឍធនធានធម្មជាតិឲ្យមានតម្លាភាព ដើម្បីបង្កើន ចំណូលប្រជារាស្ត្រ និងថវិកាជាតិ។ ពង្រីកនិងកែលំអរប្រព័ន្ធធារាសាស្ត្រ ឲ្យមានលក្ខណៈកាន់តែទំនើប ដើម្បីស្រោចស្រពផ្ទៃដីកសិកម្ម ផ្តល់ពូជ និងបច្ចេកទេសទំនើប និង ជួយរកទីផ្សារលក់កសិផលជូនប្រជារាស្ត្រ ។ លើកទឹកចិត្តអ្នកវិនិយោគទុន ឲ្យធ្វើវិនិយោគ លើវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យនានា ដោយរក្សាឲ្យបាននូវធនធានធម្មជាតិ និង បរិស្ថាន។

១០ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** លុបបំបាត់ការរំលោភបំពានយកដីធ្លីរបស់ប្រជារាស្ត្រ ដោយធ្វើការបែងចែកដីធ្លី ធ្វើប័ណ្ណកម្មសិទ្ធិទូទៅទូទាំងប្រទេស មិនប្រកាន់និន្នាការនយោបាយ និងដោះស្រាយដីសង្គមកិច្ច ជូនប្រជារាស្ត្រក្រីក្រ ដែលខ្វះដីសម្រាប់សាងសង់លំនៅដ្ឋាន និងដីបង្កបង្កើនផលឲ្យមានជីវភាពសមរម្យ និងដោះស្រាយដីបម្រុងទុក សម្រាប់កំណើនប្រជារាស្ត្រ។

១១ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ដឹកនាំកម្ពុជាឈរលើនីតិរដ្ឋ ជាសង្គមស្អាតស្អំ មានសីលធម៌ យុត្តិធម៌ ឯកភាពជាតិ ស្រឡាញ់រាប់អាន និងជួយគ្នាទៅវិញទៅមកដោយមិនរើសអើងនិន្នាការនយោបាយ។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** លើកកម្ពស់នីតិរដ្ឋ គោរពសិទ្ធិមនុស្ស និង គោលការណ៍លទ្ធិប្រជាធិបតេយ្យ ព្រមទាំងគោរពគោលការណ៍ច្បាប់ "បុគ្គលគ្រប់រូបស្មើគ្នាចំពោះមុខច្បាប់" ដោយធ្វើច្បាប់ឲ្យបានគ្រប់គ្រាន់ស៊ីសង្វាក់ រៀបចំកែទំរង់ស្ថាប័នរដ្ឋ ឲ្យបានសមស្របតាមតម្រូវការសង្គម និងអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាព។

១២ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ពិនិត្យឡើងវិញនូវការកាត់ក្តីទាំងឡាយណា ដែលអយុត្តិធម៌ ដើម្បីផ្តល់យុត្តិធម៌ជូនប្រជារាស្ត្រវិញ និងពិនិត្យទ្រព្យសម្បត្តិរបស់រដ្ឋ ដែលបានបាត់បង់ដោយខុសច្បាប់ ប្រគល់ជូនរដ្ឋវិញ។

១៣ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** លុបបំបាត់ការជួញដូរមនុស្ស ស្ត្រី និងកុមារ និង លុបបំបាត់ការផលិតការចរាចរ ការចែកចាយ និងការជួញដូរគ្រឿងញៀនខុសច្បាប់ គ្រប់ប្រភេទ។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ជម្រុញការអនុវត្តច្បាប់ឲ្យបានម៉ឺងម៉ាត់ ពិសេសច្បាប់ប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ **គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** ចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីគ្រប់គ្រងការធ្វើចំណាកស្រុកឲ្យបានស្របច្បាប់ និងមានសុវត្ថិភាពធានាការគោរពសិទ្ធិមនុស្ស ស្របតាមច្បាប់ការងារ។ ច្បាប់លក្ខន្តិកៈ និងក្រមសីលធម៌ វិជ្ជាជីវៈមន្ត្រីតុលាការ ព្រមទាំងឲ្យមន្ត្រីថ្នាក់ដឹកនាំត្រូវប្រកាសទ្រព្យសម្បត្តិ មុន និងក្រោយចូលកាន់តំណែង។

១៤ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ពិនិត្យនិងដោះស្រាយករណីជនអន្តោប្រវេសន៍ ដោយអនុវត្តច្បាប់អន្តោប្រវេសន៍ និងច្បាប់សញ្ជាតិឲ្យបានត្រឹមត្រូវ ជាពិសេសជនបរទេស ទាំងឡាយណាដែលមករស់នៅក្នុងប្រទេសកម្ពុជាដោយខុសច្បាប់។

១៥ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** លុបបំបាត់អំពើពុករលួយ និងអំពើរំលោភអំណាច ការយកកំរៃសេវាសាធារណៈនានា ដោយខុសច្បាប់ពីប្រជារាស្ត្រ និងផ្តន្ទាទោសចំពោះមន្ត្រី ដែលបានប្រព្រឹត្តខុសច្បាប់។

១៦ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ពង្រឹងនិងអភិវឌ្ឍសមត្ថភាព គុណភាព អព្យាក្រឹតភាពឯករាជ្យភាព នៃមន្ត្រីតុលាការ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ធានានូវស្ថិរភាពនយោបាយ និងការបោះឆ្នោត ដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ព្រមទាំងឲ្យព្រះសង្ឃ បុព្វជិតសាសនា មន្ត្រីតុលាការ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ស្ថិតនៅអព្យាក្រឹតឥតលំអៀង។

១៧ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** ធ្វើការបង្កើនគុណភាពអប់រំ មានគោលនយោបាយលើកទឹកចិត្តដល់សិស្ស និស្សិតពូកែ ផ្តល់អាហារូបករណ៍ជូនសិស្ស និស្សិតក្រីក្រ ព្រមទាំង បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យបានច្រើននៅមូលដ្ឋាន តាមតម្រូវការទីផ្សារការងារ ដើម្បីផ្តល់ការងារជូនប្រជារាស្ត្រ។

**គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** អភិវឌ្ឍធនធានមនុស្ស ដោយបង្កើនគុណភាពអប់រំ ពិនិត្យនិងកែសម្រួលកម្មវិធីសិក្សាឡើងវិញ ផ្លាស់ប្តូរពេលម៉ោងឲ្យសិស្សរៀនពេញមួយថ្ងៃ ពង្រឹងគុណភាពនិងសមត្ថភាពគ្រូ និងសាស្ត្រាចារ្យ និងលើកទឹកចិត្តដល់សិស្ស និស្សិតពូកែ ផ្តល់អាហារូបករណ៍ជូនសិស្ស និស្សិតក្រីក្រ។

១៨ **គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច** បង្កើនការពង្រឹងគុណភាព សេវាសុខាភិបាល និង សង្គមកិច្ចដោយលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់សេវាមិនយកកំរៃ ចំពោះប្រជារាស្ត្រក្រីក្រកាត់បន្ថយអត្រាមរណៈភាពមាតា ទារក និងកុមារ ព្រមទាំងជម្រុញឲ្យពេទ្យឯកជនជួយព្យាបាលប្រជារាស្ត្រ ដែលគ្រោះថ្នាក់ចរាចរ ដោយរដ្ឋជាអ្នកចេញថ្លៃសេវាជូន។

**គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** ផ្តល់សេវាជូនស្ត្រីមានផ្ទៃពោះ ឲ្យទៅពិនិត្យផ្ទៃពោះ នៅមន្ទីរពេទ្យរដ្ឋ ដោយឥតបង់ប្រាក់ និងលើកទឹកចិត្តដល់គ្រួសារក្រីក្រ នាំយកបុត្រធីតា អាយុ៦ឆ្នាំ ចូលរៀនថ្នាក់ទី១ ព្រមទាំងបង្កើតមណ្ឌលទទួលថែទាំ និងចិញ្ចឹមជនចាស់ជរាគ្មានទីពឹងឲ្យបានថ្លៃថ្នូរ និងសមរម្យសមនឹងប្រទេសកាន់ព្រះពុទ្ធសាសនា។

**គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** លុបបំបាត់បញ្ហាគ្រូពេទ្យមិនយកចិត្តទុកដាក់ចំពោះ អ្នកជម្ងឺ បញ្ហាទារយកលុយកាក់ពីអ្នកជម្ងឺខុសច្បាប់ ដោយមានគោលនយោបាយផ្តល់ប្រាក់ លើកទឹកចិត្តចំពោះគ្រូពេទ្យគំរូ។

**គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច** បង្កើនគុណភាព និងសុវត្ថិភាពនៃការចិញ្ចឹមទារក កុមារកំព្រា និងអ្នកកំពុងទទួលសេវាស្តារយុវនីតិ សម្បទា នៅក្នុងមណ្ឌលរដ្ឋ និងអង្គការ មិនមែនរដ្ឋាភិបាល ដោយផ្តល់អាហារ ការស្នាក់នៅសមរម្យ និងផ្តល់សេវាអប់រំ ព្រមទាំង បណ្តុះ បណ្តាវិជ្ជាជីវៈជំនាញ តាមតម្រូវការទីផ្សារការងារ។